Media Release

សម្រាប់ការចេញផ្សាយភ្លាមៗ

# សន្តិសុខទឹក ក្នុងតំបន់ទន្លេមេគង្គ និងសម្រាប់អាស៊ាន ជាគន្លឹះឆ្ពោះទៅកាន់អនាគតដែលមានសុវត្ថិភាព និងចីរភាព

**ទីក្រុងវៀងចន្ទ ប្រទេសឡាវ ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១** – កិច្ចសន្ទនាលើកដំបូងស្តីពីសន្តិសុខទឹក រវាងសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ និង គណៈកម្មការទន្លេមេគង្គ (ហៅកាត់ថា MRC) ដែលបានប្រព្រឹត្តទៅកាលពីសប្តាហ៍មុន បានលើកឡើងនូវដំណោះស្រាយលើប្រធានបទចំនួនបី ពាក់ព័ន្ធនឹងគោលនយោបាយ បច្ចេកវិទ្យា និងភាពជាដៃគូ ដែលអាចជួយប្រទេសតាមអាងទន្លេមេគង្គ និងបណ្តាលប្រទេសអាស៊ាន ឆ្លើយតបចំពោះបញ្ហាប្រឈមនឹងសន្តិសុខទឹក ដែលតំបន់នេះកំពុងជួបប្រទះ។

លោក ផនផាសិទ្ធ ភូលីភាញ់ (Phonepaseuth Phouliphanh) ប្រធានស្តីទីនៃគណៈកម្មាធិការ MRC សម្រាប់ឆ្នាំ២០២១ បានថ្លែងថា “នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ និងរបបជលសាស្ត្រ ជាសកល គេត្រូវការភាពជាបន្ទាន់មួយសម្រាប់ស្វែងរកមាគ៌ាប្រកបដោយចីរភាព ដើម្បីធានាឲ្យតំបន់នេះមានសន្តិសុខទឹក។ វាទាមទារឲ្យមានការដឹកនាំ នវានុវត្តន៍ និងកិច្ចសហប្រតិបត្តិការជាយុទ្ធសាស្ត្រក្នុងចំណោមប្រទេសក្នុងតំបន់ និងដៃគូរបស់ប្រទេសទាំងនេះ”។

នៅកម្រិតគោលនយោបាយ មន្ត្រីជាន់ខ្ពស់ និងអ្នកជំនាញ បានជំរុញឲ្យគ្រប់ភាគី និងដៃគូទាំងអស់ បង្កើនតម្លាភាពឲ្យបានច្រើន និងការចូលរួមឲ្យកាន់តែស៊ីជម្រៅ ដើម្បីជំរុញការគ្រប់គ្រងដោយចីរភាពនៃធនធានទឹក និងធនធានពាក់ព័ន្ធសម្រាប់តំបន់អាស៊ានទាំងមូល។

កិច្ចសន្ទនារយៈពេលពីរថ្ងៃ ដែលបានបិទបញ្ចប់កាលពីថ្ងៃសុក្រ បានលើកឡើងថា គេត្រូវការវឌ្ឍនភាពនៃកំណែទម្រង់ស្ថាប័ន និងគោលនយោបាយ ដែលជួយលើកកម្ពស់ការគ្រប់គ្រងធនធានទឹកបែបចម្រុះ។ ការអំពាវនាវឲ្យមានសមាហរណកម្មតាមមូលដ្ឋាន និងថ្នាក់តំបន់កាន់តែជិតស្និត ក៏ត្រូវបានលើកឡើងដែរ ជាពិសេសលើវិស័យនានាសម្រាប់ការរៀបចំផែនការធនធានទឹក ការគ្រប់គ្រងការបំពុលបរិស្ថាន ការព្យាករណ៍និងជូនដំណឹងជាមុន និងការលើកកម្ពស់ការយល់ដឹង។

ប៉ុន្តែ បច្ចេកវិទ្យា ក៏បានដើរតួនាទីយ៉ាងសំខាន់ផងដែរ។ បច្ចេកវិទ្យាឌីជីថល និងឧបករណ៍ម៉ូឌែលទំនើបៗ ដូចជាបច្ចេកវិទ្យាបញ្ញាសប្បនិម្មិត និងបច្ចេកវិទ្យាឌីជីថលភ្លោះ ដែលនាបច្ចុប្បន្ននេះ ជាបច្ចេកវិទ្យាដ៏មានប្រសិទ្ធភាពបំផុត ក្នុងការគ្រប់គ្រងមូលដ្ឋានទិន្នន័យធនធានទឹកថ្នាក់តំបន់។ រួមជាមួយគ្នា ឧបករណ៍ទាំងនេះជួយពង្រឹងជំនាញមូលដ្ឋាន ក្នុងការគ្រប់គ្រងហានិភ័យពាក់ព័ន្ធទឹក រួមមានគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ទន្ទឹមនឹងធ្វើឲ្យប្រសើរឡើងនូវបរិមាណ និងគុណភាពទឹកស្តុក។

គណៈប្រតិភូ ក៏បានលើកជាសំណើរឲ្យបន្តចូលរួមជាមួយនឹងស្ថាប័នផ្សេងៗ និងការប្រើប្រាស់កាន់តែច្រើនឡើងនូវភាពជាដៃគូរវាងស្ថាប័នសាធារណៈ និងវិស័យឯកជន។ ការចូលរួមខ្លាំងជាមួយនឹងវិស័យឯកជន

អាចជួយគាំទ្រដល់រដ្ឋាភិបាលអាស៊ាន ប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ខណៈដែលកិច្ចសហប្រតិបត្តិការថ្នាក់តំបន់កាន់តែរឹងមាំ នឹងជួយសម្រួលឲ្យមានការផ្លាស់ប្តូរទៅវិញទៅមកនូវជំនាញគ្រប់គ្រងធនធានទឹកបែបចម្រុះ និងជំរុញឲ្យមានការវិនិយោគដោយចីរភាព។

លោក គង់ ភោគ (Kung Phoak) អគ្គលេខាធិការរងនៃអាស៊ាន ទទួលបន្ទុកសហគមន៍សង្គម និងវប្បធម៌ បានមានប្រសាសន៍ថា "ប៉ុន្មានឆ្នាំមកនេះ ការថែរក្សាធនធានទឹកតំបន់ បានក្លាយជាកិច្ចការស្នូលមួយរបស់អាស៊ាន"។ លោកបានរំលេចពីគុណតម្លៃនៃការលើកកម្ពស់កិច្ចសហប្រតិបត្តិការតំបន់ និងការពង្រឹងចំណងទំនាក់ទំនងក្នុងចំណោមប្រទេសអាស៊ាន ដើម្បីឆ្លើយតបទៅនឹងបញ្ហាទឹកដែលកើតមាន រួមទាំងការទទួលបានដោយសមធម៌នូវទឹកមានសុវត្ថិភាព និងតម្លៃសមរម្យ ការផ្គត់ផ្គង់ទឹកគ្រប់គ្រាន់ ដើម្បីធានាឲ្យមានសន្តិសុខស្បៀង ដើម្បីទ្រទង់ដល់សេដ្ឋកិច្ចតំបន់ និងដំណោះស្រាយដោយចីរភាព ដែលអាចកាត់បន្ថយគ្រោះមហន្តរាយពាក់ព័ន្ធទឹក។

ប្រជាជនជាង ៧០ លាននាក់ ពឹងពាក់អាស្រ័យខ្លះ ឬទាំងស្រុងលើទន្លេមេគង្គ ធ្វើជាប្រភពមួយនៃចំណូល និងជាប្រភពមួយនៃជីវិត។ ក៏ប៉ុន្តែ បញ្ហាឆ្លងដែនដែលកំពុងកើតមាន បានឈានមកដល់ចំណុចសំខាន់មួយ នៅតាមផ្នែកជាច្រើននៃតំបន់អាស៊ានទាំងមូល ដែលទាមទារឲ្យមានការរួបរួមក្នុងតំបន់កាន់តែខ្លាំង និងស៊ីជម្រៅជាងមុន ដើម្បីលុបបំបាត់គម្លាតនៃការអភិវឌ្ឍ។

ម៉ូឌែលថ្មីៗពី MRC ស្តីពីផលប៉ះពាល់នៃការអភិវឌ្ឍតំបន់ ដែលបានបង្ហាញឲ្យឃើញថា ការធ្លាក់ចុះផ្នែកបរិស្ថាន មានស្ថានភាពកាន់តែអាក្រក់ ក្នុងរយៈពេល ២៥ ឆ្នាំចុងក្រោយនេះ ចាប់តាំងពី MRC បង្កើតមក។

អនុសាសន៍មួយចំនួនដែលបានពិភាក្សា ក្នុងអំឡុងនៃកិច្ចសន្ទនា អាចបង្កើតបានមូលដ្ឋានគ្រឹះ សម្រាប់យន្តការតំបន់មួយ ដែលជួយពង្រឹងកិច្ចសន្ទនា និងការសម្របសម្រួល។ ដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់នៃសកម្មភាពរបស់មនុស្ស និងវិសមភាពរវាងប្រទេស ទាមទារឲ្យមានការផ្លាស់ប្តូរកាន់តែច្រើននៃព័ត៌មាន ក៏ដូចជាជំនួយផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ក្នុងចំណោមប្រទេសអាស៊ាន និងដៃគូអភិវឌ្ឍន៍។

កិច្ចសន្ទនាស្តីពីសន្តិសុខទឹកលើកទី១ រវាងអាស៊ាន និង MRC ត្រូវបានកសាងលើក្របខ័ណ្ឌសហការរវាងអាស៊ាន និង MRC ដែលបានចុះហត្ថលេខា កាលពីឆ្នាំ២០១៨។ លេខាធិការដ្ឋាន MRC និងប្រទេសតាមអាងទន្លេមេគង្គក្រោម រួមជាមួយនឹងប្រទេសសមាជិកអាស៊ាន បានប្តេជ្ញាចិត្តសម្រេចឲ្យបាននូវគោលបំណងនៃកិច្ចព្រមព្រៀងទន្លេមេគង្គ ឆ្នាំ១៩៩៥ និងទស្សនៈវិស័យរបស់អាស៊ាន សម្រាប់សន្តិសុខទឹក នៅឆ្នាំ២០២៥ តាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួល។

ស្របពេលដែលកិច្ចសន្ទនាលើកទី១ បានផ្តោតលើការផ្លាស់ប្តូរ និងដំណោះស្រាយផ្នែកបច្ចេកទេស ក្នុងចំណោមមន្ត្រីជំនាញ និងអ្នករៀបចំគោលនយោបាយអាស៊ាន កិច្ចសន្ទនាលើកទី២ ដែលបានគ្រោងសម្រាប់ឆ្នាំ២០២៣ នឹងអាចផ្តោតលើកិច្ចពិភាក្សាស្តីពីគោលនយោបាយ ដែលនឹងមានការចូលរួមពីភាគីពាក់ព័ន្ធកាន់តែទូលំទូលាយ។

អាស៊ាន និង MRC នឹងរៀបចំកិច្ចពិភាក្សាដើម្បីរិះរកមធ្យោបាយក្នុងការប្រើប្រាស់អនុសាសន៍សំខាន់ៗនៃកិច្ចសន្ទនា នៅក្នុងសកម្មភាពគោលនយោបាយនានា។

**ចប់**

## កំណត់សម្គាល់សម្រាប់និពន្ធនាយកៈ

អាស៊ាន ប្រមូលផ្តុំដោយប្រទេសប៊្រុយណេ កម្ពុជា ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន សឹង្ហបុរី ថៃ និងវៀតណាម ក្នុងសហគមន៍មួយ ដែលរួបរួមដោយបំណងប្រាថ្នា និងឆន្ទៈរួម ក្នុងការរស់នៅក្នុងតំបន់មួយប្រកបដោយសន្តិភាព សន្តិសុខ និងស្ថិរភាពយូរអង្វែង កំណើនសេដ្ឋកិច្ចដោយចីរភាព ភាពរីកចម្រើនដោយចែករំលែក និងវឌ្ឍនភាពសង្គម និងដើម្បីលើកកម្ពស់ផលប្រយោជន៍ ឧត្តមគតិ និងបំណងប្រាថ្នាចាំបាច់សម្រាប់តំបន់នេះ។ ដើម្បីអានបន្ថែមពីអាស៊ាន សូមមើលគេហទំព័រ www.asean.org។

គណៈកម្មការទន្លេមេគង្គ គឺជាស្ថាប័នអន្តររដ្ឋាភិបាល ដែលមានតួនាទីជំរុញលើកកម្ពស់កិច្ចពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់នៅក្នុងតំបន់អាងទន្លេមេគង្គខ្សែទឹកខាងក្រោម ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ផ្អែកទៅតាមកិច្ចព្រមព្រៀងទន្លេមេគង្គ រវាងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ ស្ថាប័ននេះ បំពេញតួនាទីជាវេទិកាថ្នាក់តំបន់សម្រាប់ការទូតទឹក ក៏ដូចជាជាមជ្ឈមណ្ឌលប្រមូលផ្តុំចំណេះដឹងអំពីការគ្រប់គ្រងធនធានទឹក ដើម្បីអភិវឌ្ឍន៍តំបន់នេះប្រកបដោយចីរភាព។

## សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងៈ

លោក មាស សុភក្រ្គ មន្ត្រីទំនាក់ទំនងសម្រាប់អ្នកសារព័ត៌មាន
លេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គ
អ៊ីម៉ែលៈ sopheak@mrcmekong.org

លោកស្រី Mustika Larasati Hapsoro មន្ត្រីផ្នែកសារព័ត៌មាន
ផ្នែកទំនាក់ទំនងសហគមន៍នៃលេខាធិការដ្ឋានអាស៊ាន
ទូរស័ព្ទៈ +៦២-២១៧២៤៣៣៧២
អ៊ីម៉ែលៈ mustika.hapsoro@asean.org

###